**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ :** ត្រូវបានបង្កើតនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ ចំណុះផ្ទាល់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** ការបង្កើតនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌនេះ មានគោលបំណងការពារសណ្តាប់ធ្នាប់សាធារណៈ ការទប់ស្កាត់ និងបង្ក្រាបបទល្មើសដែលពាក់ព័ន្ធបេតិកភណ្ឌប្រវត្តិសាស្ត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## រចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា ៣ :** នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៤ :** នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ មានការិយាល័យជំនាញ និងអង្គភាពមួយចំនួនជាចំណុះ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

**មាត្រា ៥ :** ការបង្កើតការិយាល័យនគរបាលការពារបេតិកភណ្ឌចំណុះស្នងការដ្ឋាននគរបាលខេត្តក្រុង យោងទៅតាមតំរូវការចាំបាច់របស់ខេត្តក្រុងនិមួយៗ ដែលត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

## តួនាទី និងភារកិច្ច

**មាត្រា ៦ :** នាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ មានតួនាទី និងភារកិច្ចដូចតទៅ:

- លើកទិសដៅផែនការដឹកនាំបញ្ជានគរបាលការពារបេតិកភណ្ឌ អនុវត្តភារកិច្ចការពារ ថែរក្សាអោយបានស្ថិតស្ថេរគង់វង្សនូវសារពើបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្ររបស់ជាតិ
- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា និងអាជ្ញាធរនានាដែលពាក់ព័ន្ធដល់កិច្ចការពារបេតិកភណ្ឌដើម្បីប្រមែប្រមូលរបាយការណ៍ព័ត៌មាន និងទទួលបញ្ជីសារពើភណ្ឌបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រជាតិក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីបំរើសំណូមពរនៃកិច្ចប្រតិបត្តិការគ្រប់គ្រង និងថែរក្សាការពារអោយបានស្ថិតស្ថេរគង់វង្ស
- ស្រាវជ្រាវ និងលើកយោបល់អំពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសច្បាប់ ការបំផ្លិចបំផ្លាញ ការលួចលាក់ ការប្លន់ ការលក់ទិញ ការដឹកជញ្ជូនបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រជាតិ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន
- ចាត់តាំងស៊ើបអង្កេត និងត្រួតពិនិត្យផែនការចាប់ខ្លួនជនល្មើសដែលពាក់ព័ន្ធដល់ការបង្កគ្រោះមហន្តរាយ បំផ្លិចបំផ្លាញ ការលួចលាក់ ការប្លន់ ការលក់ទិញ ការដឹកជញ្ជូនបេតិកភណ្ឌសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រជាតិ ដើម្បីកសាងសំណុំរឿង និងបញ្ជូនជនល្មើសព្រមទាំងវត្ថុតាងទៅតុលាការផ្តន្ទាទោសតាមច្បាប់
- សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបជនល្មើសដែលបង្កគ្រោះមហន្តរាយ បំផ្លិចបំផ្លាញដល់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ
- ធ្វើទំនាក់ទំនងជាមួយអង្គការយូណេស្កូ អង្គការជាតិ និងអន្តរជាតិនានា ដើម្បីទទួលការណែនាំផ្សព្វផ្សាយគោលការណ៍ និងទទួលជំនួយឧបត្ថម្ភបំរើសេវាការពារបេតិកភណ្ឌសម្បត្តិវប្បធម៌ជាតិ
- សហការជាមួយនគរបាលទេសចរណ៍ក្នុងកិច្ចការពារសុវត្ថិភាព សន្តិសុខភ្ញៀវជាតិ និងអន្តរជាតិដែលមកបំពេញបេសកម្មធ្វើទស្សនកិច្ច ឬធ្វើទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រដែលស្ថិតនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន
- អនុវត្តវិធានការមុខជំនាញនានា តាមគោលការណ៍ដឹកនាំរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ
- បូកសរុបធ្វើសេចក្តីរាយការណ៍តាមការកំណត់ ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗដែលពាក់ព័ន្ធដល់ការអនុវត្តន៍ភារកិច្ចការពារបេតិកភណ្ឌខេត្តក្រុង មកអគ្គស្នងការដ្ឋាននគរ - បាលជាតិ និងក្រសួងមហាផ្ទៃ

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និងកិត្តិយសរបស់នគរបាលការពារបេតិកភណ្ឌ
- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យ របស់នាយកដ្ឋានខ្លួនតាមការកំណត់របស់ក្រសួងមហាផ្ទៃ
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧ :** អនុក្រឹត្យលេខ ១២១អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធរបស់ស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ អោយទៅជាការិយាល័យនគរបាលការពារបេតិកភណ្ឌ និងការិយាល័យនគរបាលទេសចរណ៍ ចំណុះស្នងការដ្ឋាននគរបាលខេត្តសៀមរាប អនុក្រឹត្យលេខ ៦០អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១១៩៧ ស្តីពីការបង្កើតស្នងការដ្ឋានពិសេសការពារបេតិកភណ្ឌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តក្រុងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៨*
- *កាលប្បវត្តិ-ឯកសារ*

***បានយកសេចក្តីជំរាបជូន***

***សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា***

**ស ខេង**

***ឧបនាយករដ្ឋមន្ត្រី***

***រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ***